# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៥៦ ស្តីពីការតែងតាំងលោក **តាំង ខូនសុខ** ជាឧកញ៉ា ៧០៦

០៨-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៥៩ ស្តីពីការផ្លាស់ប្តូរតែងតាំង និងបែងចែកភារកិច្ចជូនឯកអគ្គរាជទូត ប្រចាំនៅបរទេស នូវ ឯកឧត្តម លោកជំទាវចំនួន ០៤ រូប ៧០៧

១២-៤-២០០៤ -Kret NS/KRT/0404/060 ELEVONS... ៧០៩

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦១ ស្តីពីការតែងតាំងលោកជំទាវបណ្ឌិត **សឿង រដ្ឋចាវី** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៧១០

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦២ ស្តីពីការតែងតាំងឯកឧត្តម **ហ៊ុយ សេដ្ឋ** ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានឋានៈស្មើ **អគ្គនាយក** ៧១១

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ប្យុងហាក់** (KIM BYOUNG HAK) សញ្ជាតិដើមកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៧១២

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី យ៉ុងណាំ** (LEE YONG NAM) សញ្ជាតិដើមកូរ៉េ កើតនៅខេត្ត Iksan សាធារណរដ្ឋកូរ៉េ ៧១៣

៣០-៤-២០០៤ ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៨ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **លូ គឹមឈន់** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៧១៤


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


១៦-៤-២០០៤ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពីការប្រែក្លាយវិទ្យាស្ថានគ្រប់គ្រង ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង ៧១៥

២៨-៤-២០០៤ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទបេងមាលា ៧១៨

៣០-៤-២០០៤ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យខេមរៈ ៧២៣

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព ៧២៦

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧២៧

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧២៨

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧២៩
២៧-៤-២០០៤ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៣០
២៧-៤-២០០៤ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣១
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣២
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៣
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៤
២៩-៤-២០០៤ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤២
៣០-៤-២០០៤ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៤

## ២.សេចក្តីសំរេច

១៩-៤-២០០៤ -សេចក្តីសំរេចលេខ ២០ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧៤៥
២០-៤-២០០៤ -សេចក្តីសំរេចលេខ ២១ សសរ ស្តីពីការបង្កើតក្រុមការងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំលើកទី ២ រវាងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ៧៤៦
២៥-៤-២០០៤ -សេចក្តីសំរេចលេខ ២២ សសរ ស្តីពីការផ្ទេរសិទ្ធិការងារ ៧៤៨
២៦-៤-២០០៤ -សេចក្តីសំរេចលេខ ២៣ សសរ ស្តីពីការបង្កើតគណៈកម្មការ សម្របសម្រួល និងគ្រប់គ្រងគំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ ( ភ្នំពេញ ) ទៅដល់ទីរួមខេត្តកំពត ៧៤៩

## III.ការងារបណ្តាក្រសួង

## ធនាគារជាតិនៃកម្ពុជា

២៩-៤-២០០៤ -ប្រកាសលេខ ធ ៦.០៤-០៦២ ប្រក ស្តីពី រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ៧៥០

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៩៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

លោក តាំង វួនសុង

ជា

## ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសំបន្ទាប់

ប្រមុខរដ្ឋស្តីទី

ពរល.០៤.០៤.០៩៦   លេខៈ ៤៣ ច.ល   ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៥៩

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានផ្លាស់ប្ដូរតែងតាំង និងបែងចែកភារកិច្ច ជូនឯកអគ្គរាជទូត ប្រចាំនៅបរទេស នូវឯកឧត្ដម លោកជំទាវ ចំនួន ០៤ រូប ដែលមានរាយនាមដូចខាងក្រោម:

១-តែងតាំង លោកជំទាវ **ស៊ុន សារឿន** បច្ចុប្បន្នអនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា អមសហភាពអឺរ៉ុប ព្រមទាំងប្រចាំប្រទេសបែលហ្ស៊ិក អូទ្រីស ហូឡង់ និងលុចហ្សំបួរ ដែលមាននិវេសនដ្ឋាននៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក ។

២-តែងតាំង ឯកឧត្តម **ហោ ណាំបូរ៉ា** បច្ចុប្បន្នឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងញូវែលហ្សេឡង់ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំចក្រភពអង់គ្លេស និងជាឯកអគ្គរាជទូតតែងតាំង ប្រចាំប្រទេសដាណឺម៉ាក បុ៉ូឡូញ ន័រវែស និងស៊ុយអែត ដែលមានទីលំនៅនៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ។

៣-តែងតាំង ឯកឧត្តម **អ៊ុជ គឹមអន** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង និងជាឯកអគ្គរាជទូតតែងតាំង ប្រចាំប្រទេសអេស្ប៉ាញ អ៊ីតាលី និងព័រទុយហ្កាល់ ដែលមានទីលំនៅនៅទីក្រុងប៉ារីស ប្រទេសបារាំង ។

៤-តែងតាំង ឯកឧត្តម **មាស គឹមហេង** បច្ចុប្បន្នអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងញូវែលហ្សេឡង់ ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៤

តួងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

មគ្គុទ្ទេសក៍... 

មគ្គុ

ជា ស៊ីម

ពរស.០៤.០៤.០៥៩

លេខ: ៤៤ ចប

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៤

រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី

ណាឌី តាន់

# KRET

( Palais Royal )

NS/KRT/0404/060

NOUS
NORODOM SIHANOUK
ROI DU CAMBODGE

ELEVONS

I- Au rang de Ministre :

1- Son Excellence Monsieur KUY SOPHAL
2- Son Excellence Monsieur CHUM NGOEUN
3- Son Excellence Monsieur MEAK SAMPHUON

II- Au rang de Secrétaire d'Etat :

1- Son Excellence Monsieur CHHEA HORN
2- Son Excellence Monsieur AN SEAM
3- Son Excellence Monsieur UM EM

III- Au rang de Sous Secrétaire d'Etat :

1- Son Excellence Monsieur SO SINUON

IV- Au rang d'Ambassadeur :

1- Son Excellence Monsieur KEM SIEA
2- Son Excellence Monsieur LAC KY
3- Son Excellence Monsieur PHENG PHIRUN
4- Son Excellence Monsieur VANN VAN
5- Son Excellence Monsieur MEAS REN
6- Son Excellence Monsieur CHHENG HUOT
7- Son Excellence Monsieur YOU SAM EL

V- Au rang de Ministre - Conseiller :

1- Madame HANG SOKAN
2- Madame TAN SOKHA
3- Monsieur NEP CHANREASMEY
4- Monsieur NUON VANNAK
5- Monsieur TAN POK
6- Monsieur MEN VUTHY
7- Monsieur YIM VINAVUTH
8- Monsieur HY SAMAN
9- Monsieur BAN NON

VI- Au rang de Premier Secrétaire d'Ambassade :

1- Madame SOK KAN
2- Madame KHLOT RASMEY
3 Madame THAN RACHANA
4- Monsieur HO DINO

Fait le 12 Avril 2004

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ:០០១/០៤ រ.ធធ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៤

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង

ហត្ថលេខា

គង់ សំអុល

លេខ: ៤៥ លអ

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

... ឈារី ...

៣៧៧.០៤.០៤.០៦០

បានប្រថាប់ព្រះរាជលញ្ឆករួចហើយ

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវបណ្ឌិត **សឿង រដ្ឋចាវី** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរាជសាំង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខៈ ៤៥ ច.ល

[illegible].០៤.០៤.០៦១ ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ង៉ុយ សេដ្ឋ ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយមានសិទ្ធិ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ: ៤៣៧.៣៣ ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤ល.០៤.០៤.០៦៧ បានថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ មេសា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឧសាឌិ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/ ០៦៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក គីម ប្យុងហាក់ (KIM BYOUNG HAK ) សញ្ជាតិដើមកូរ៉េ កើតថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៥៦ នៅ ខណ្ឌ GURO ក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ៤៦.ចល

៣៧០.០៤.០៤.០៦៣ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី យ៉ុងណាំ** ( LEE YONG NAM ) សញ្ជាតិដើមកូរ៉េ កើតថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៥៥ នៅខេត្ត Iksan សាធារណរដ្ឋកូរ៉េ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

តរល.០៤.០៤.០៦៤

លេខៈ ៤៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សណ្ឋី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ត្រាស់ព្រះរាជទាន

ជំពោះ

ឯកឧត្តម **លូ គឹមឈន់**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០០៤

ឡកព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ៥០ ច.ព

ដើម្បីចម្លងចែក

៣រស.០៤០៤.០៦៨

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៤

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ិន សេរី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយវិទ្យាស្ថានជាតិគ្រប់គ្រង ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញសេចក្តីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង និងការបើកថ្នាក់បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

មាត្រា ១ : ប្រែក្លាយ វិទ្យាស្ថានជាតិគ្រប់គ្រង ទៅជា សាកលវិទ្យាល័យជាតិគ្រប់គ្រង " NATIONAL UNIVERSITY OF MANAGEMENT " ហៅកាត់ជាភាសាខ្មែរ " ស.ជ.គ " និងហៅកាត់ជាភាសាអង់គ្លេស " NUM " ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ : សាកលវិទ្យាល័យជាតិគ្រប់គ្រង មានតួនាទីជា មជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ថែរក្សានិងលើកស្ទួយនូវអត្តសញ្ញាណជាតិ ។

មាត្រា ៣ : សាកលវិទ្យាល័យជាតិគ្រប់គ្រង ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- ថ្នាក់បណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៣ ឆ្នាំ

មាត្រា ៤ : សាកលវិទ្យាល័យជាតិគ្រប់គ្រង មាន ៦ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យគ្រប់គ្រង

២. មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យ

៣. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច

៤. មហាវិទ្យាល័យសេដ្ឋកិច្ច

៥. មហាវិទ្យាល័យនីតិសាស្ត្រ

៦. មហាវិទ្យាល័យព័ត៌មានវិទ្យា

និង ថ្នាក់ក្រោយបរិញ្ញាប័ត្រ ។

សាកលវិទ្យាល័យនេះ មានសាខាមួយ ស្ថិតនៅទីរួមខេត្តបាត់ដំបង ។ ទៅអនាគត សាកលវិទ្យាល័យជាតិគ្រប់គ្រង អាចបើកសាខា មហាវិទ្យាល័យ ឯកទេស កំរិត ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៦ : សាកលវិទ្យាល័យជាតិគ្រប់គ្រង ដឹកនាំដោយ សាកលវិទ្យាធិការមួយរូប ដែលមានការតែងតាំងដោយព្រះរាជក្រឹត្យ និងមានសាកលវិទ្យាធិការរង ជាជំនួយការ តាមតំរូវការចាំបាច់ ដែលតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា ៧** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ

"ដើម្បីមុខការ"

- ដូចមាត្រា ៨

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ -ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់រមណីយដ្ឋានប្រាសាទបេងមាលា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ ០០១នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ " អប្សរា "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្ដីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការ បង្កើតអាជ្ញាធរ " អប្សរា "
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤

# សំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានប្រាសាទបេងមាលា ជាតំបន់ការពារស្ថិតនៅក្នុងភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ផ្អែកទៅតាមព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានបំណង :

-អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិសាស្ត្រ និងលើកតម្លៃពន្ធុរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត

-អភិរក្សទេសភាព វប្បធម៌ និងអភិវឌ្ឍតំបន់ទេសចរណ៍

-ការពារបរិស្ថានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង និងអនុវត្តតាមគោលការណ៍នានាដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

## ជំពូកទី ២

## ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យមានការត្រួតពិនិត្យ រាល់ការអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋានការពារដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់ដែលត្រូវការពារ ។

មាត្រា ៤.-

រមណីយដ្ឋានការពារប្រាសាទបេងមាលា កំណត់ជាពីរតំបន់ផ្សេងគ្នា ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក.តំបន់ ១ : រមណីយដ្ឋានមានប្រាសាទ គឺជាតំបន់ដែលមានស្ថានីយបុរាណវត្ថុសំខាន់ៗជាងគេ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។ តំបន់នេះ មានចម្ងាយប្រវែង១៥០ម៉ ( មួយរយហាសិបម៉ែត្រ) ពីកំពែងប្រាសាទក្រៅបំផុត ដល់ខ្សែបន្ទាត់និយាមកានៃចំណុចដូចតទៅ :

| | | |
|---|---|---|
| A0 (416080 ; 1489350) | , | A6 (419150 ; 1489550) |
| A1 (416140 ; 1490400) | , | A7 (418360 ; 1489520) |
| A2 (417260 ; 1490400) | , | A8 (417570 ; 1489500) |
| A3 (417260 ; 1490470) | , | A9 (417200 ; 1489490) |
| A4 (419300 ; 1490470) | , | A10 (417130 ; 1489360) |
| A5 (419300 ; 1489560) | , | A11 (416560 ; 1489370) |

តំបន់ទី ១នេះ មានផ្ទៃក្រឡា ៣១៥ ហ.ត ៣ ( បីរយដប់ប្រាំហិកតា និងបីអារ )

ខ.តំបន់ ២ : ឧទ្យានបុរាណវត្ថុត្រូវការពារ គឺតំបន់ដែលសម្បូរសំណល់បុរាណវត្ថុដែលត្រូវការពារទប់ទល់នឹងការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍន៍មិនសមស្រប និងត្រូវមានការវាយតម្លៃផលប៉ះពាល់ដល់បរិស្ថាន ។ តំបន់នេះមានចម្ងាយប្រវែង ២៥០ម៉ ( ពីររយហាសិបម៉ែត្រ ) ពីខ្សែបន្ទាត់និយាមកា A0........A11 ដល់ខ្សែបន្ទាត់និយាមកានៃចំណុចដូចតទៅ :

| | | |
|---|---|---|
| B0 (415770 ; 1489130) | , | B4 (419550 ; 1490700) |
| B1 (415770 ; 1490650) | , | B5 (419550 ; 1489310) |
| B2 (417030 ; 1490630) | , | B6 (417350 ; 1489250) |
| B3 (417030 ; 1490710) | , | B7 (417300 ; 1489120) |

តំបន់ទី ២ នេះមានផ្ទៃក្រឡា ២៤១ ហត ៦ (ពីររយសែសិបមួយហិកតា និងប្រាំមួយអារ)

ចំពោះតំបន់ទី ៣ តំបន់ទី ៤ និងតំបន់ទី ៥ កំរិតការពារមានចែងនៅក្នុងព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ។

## ជំពូកទី ៣
## ការកែប្រែតំបន់

មាត្រា ៥.-

តំបន់នីមួយៗត្រូវបានគ្រប់គ្រង ថែទាំ និង ការពារស្របតាមទិសដៅសំរាប់តំបន់ត្រូវការពារសៀមរាបអង្គរ ។ បរិវេណ និងភាពសក្តានុភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទបេងមាលា អាចត្រួតពិនិត្យឡើងវិញ ហើយកែប្រែបានដោយផ្អែកលើភាពលេចធ្លោនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងភាពជាក់ស្តែងដើម្បីការពារការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រសើរដោយនិន្នាការដូចមានចែងក្នុង មាត្រា ៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


AUTORITE APSARA
DEPARTEMENT DES MONUMENTS
ET DE L'ARCHEOLOGIE

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧ អនក្រ.បក**

៣៣៣៣៣៣

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យខេមរៈ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតរបស់លោក នូ ចាន់សុភី ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## ស ំ រ េ ច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យខេមរៈ Khemarak University ហៅកាត់ជាភាសាខ្មែរ "ស.ខ." និងហៅកាត់ជាភាសាអង់គ្លេស " K.U."។

សាកលវិទ្យាល័យខេមរៈ មានទីតាំងស្ថិតនៅអាគារប្រផេះ មហាវិថីព្រះសីហនុ (២៧៤) កែងនឹងផ្លូវសម្តេចសុធារស (៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យខេមរៈ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យខេមរៈ ធ្វើការបណ្តុះបណ្តាលថ្នាក់ :

- បរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បណ្ឌិតសិក្សាស្រាវជ្រាវរយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យខេមរៈត្រូវរៀបចំកម្មវិធីសិក្សាលំអិតដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យខេមរៈ មាន ៧ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ
២. មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
៣. មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និង ទំនាក់ទំនងអន្តរជាតិ
៤. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
៥. មហាវិទ្យាល័យមនុស្សសាស្ត្រ សិល្បៈ និងភាសាវិទ្យា
៦. មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ
៧. មហាវិទ្យាល័យវិទ្យាសាស្ត្របច្ចេកវិទ្យា និងព័ត៌មានវិទ្យា

និង មានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្រាវជ្រាវមួយ ។

ទៅអនាគត សាកលវិទ្យាល័យខេមរៈ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : សាកលវិទ្យាល័យខេមរៈ មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និងក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រមួយ សំរាប់អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងល័ក្ខខ័ណ្ឌទទួលនិស្សិតអោយចូលរៀន សាកលវិទ្យាល័យខេមរៈត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីការទទួលនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យខេមរៈ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវការងារសិក្សា ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាបត្រ ។

- គោរព និងអនុវត្តតាម បទដ្ឋានរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។
- ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យខេមរៈ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យខេមរៈ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យខេមរៈ មានភារកិច្ចអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនដំណឹង"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៧១៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១ ៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.តត ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងអភិបាលរងខេត្ត ក្រុង
- យោងសេចក្តីចម្លងសំបុត្រមរណភាពរបស់លោក **ឈឹម ឆាម** លេខ ០១ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានលុបឈ្មោះលោក **ឈឹម ឆាម** អភិបាលរងទី ១ ខេត្តស្វាយរៀង ដែលបានទទួលមរណភាពកាលពីថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៤ ដោយរោគាពាធ ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- កាលប្បវត្តិ ឯកសារ ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបាន បរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងរូបសំណាក លោកតាដំបងក្រញូង ឧបត្ថម្ភអង្ករ សារុង ទឹកស៊ីអ៊ីវ និង ថវិកា ប្រគេនព្រះសង្ឃ និង ជូនប្រជាពលរដ្ឋ នៅក្នុងស្រុកបាត់ដំបង ស្រុកឯកភ្នំ និង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **ខ្វាន់ សារនត** និង អ្នកស្រី **សោ គំណន្ទ** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣២.០០០ ដុល្លារ

២-លោក **ចំន្ទ សុវណ្ណរិទ្ធ** ហៅគ្រូក្មេង នៅខេត្តបាត់ដំបង ថវិកា ចំនួន ១២.៦៤០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤២៣ អនក.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងកុដិ ០១ខ្នង មាន ១២ បន្ទប់ ព្រមទាំងបំពាក់គ្រឿង សង្ហារិម និង កុំព្យូទ័រ ចំនួន ០៣គ្រឿង នៅក្នុងវត្តមហាមន្ត្រី សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ឆុំ ស៊ីម៉ាច់** | ទីប្រឹក្សាសម្តេចព្រះសង្ឃរាជ ទេព វង្ស និង ជាប្រធានសាងសង់ វត្តមហាមន្ត្រី បច្ច័យ ចំនួន ២១.០៥៣ ដុល្លារ | |
| ២-លោកស្រី | **ខៀវ ចរន្តា** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.៤៥០ ដុល្លារ |
| ៣-លោក | **សាត សក្ការៈ** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.៣៥៩ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ចាម

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកតាព្រឹទ្ធាចារ្យ **ចាយ គឹមហុង** ហៅ លោកគ្រូ **ចាម ទុំយ** ដែលមានស្នាដៃល្អ ក្នុងការថែរក្សាបេតិកភណ្ឌវប្បធម៌ និង ការពារទំនៀមទំលាប់ប្រពៃណីជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៤១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ក្រសួងសុខាភិបាល

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតែងតាំងលោកស្រីវេជ្ជបណ្ឌិត **យក់ សម្បត្តិ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០០៤
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៤ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៤រូប ដែលបាន បរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងព្រះវិហារ វត្តចំប៉ាចារ្យ ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមាន រាយព្រះនាម និង នាមខាងក្រោមនេះ :-

| | | |
|---|---|---|
| ១-ព្រះតេជគុណ **ជ័យ ឆន** | ព្រះចៅអធិការវត្តចំប៉ាចារ្យ | បច្ច័យចំនួន ១១.៣០០ ដុល្លារ |
| ២-ព្រះតេជគុណ **សួន ស៊ីនួន** | គង់នៅប្រទេសអូស្ត្រាលី | បច្ច័យចំនួន ១០.២០០ ដុល្លារ |
| ៣-លោកស្រី **ខឹម ស្រ៊ី** និង អ្នកស្រី **ញ៉ឹម ឆៀង** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១៥.៩៥០ ដុល្លារ |
| ៤-ឧបាសិកា **អួន** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១១.៥០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

188

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...១២៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រ េ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក **ខិត ពិជ័យ** សប្បុរសជនខ្មែរនៅប្រទេសជប៉ុន ដែលបានបរិច្ចាគ ធនធាន ជួយកសាងសមិទ្ធផលនានា ក្នុងវិស័យអប់រំ និង វិស័យគមនាគមន៍ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ចំណាយថវិកាអស់ចំនួន ១០២.២៥០ ដុល្លារ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២២៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
